រដ្ឋាភិបាល កម្ពុជា

លេខ .....ខុទ្ទ-៩៦

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ជម្រាបជូន

### សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា

សម្តេចជាទីរាប់អានដ៏ខ្ពង់ខ្ពស់

យោងតាមលិខិតរបស់ឯកឧត្ត ចែម ស្គួន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លេខ៦១ ព្រម.ភព.៩៦ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៦ ស្តីអំពីការដកហូតសម្ភារៈពីជនល្មើស ខ្ញុំមានកិត្តិយស សូមជម្រាបសម្តេចថាៈ

១-ខ្ញុំយល់ព្រមអនុញ្ញាតឱ្យតុលាការធ្វើការចោទប្រកាន់ ក្នុងករណីដែលអង្គការសាមីទាំងឡាយមិនផ្តល់តាងឬវត្ថុដកហូតពីជនល្មើសឬក៏ផ្តល់មិនបានគ្រប់ចំនួន សំណូមពរចាំបាច់របស់តុលាការតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

២-ក្នុងន័យនេះដែរ ដើម្បីលើកទឹកចិត្តដល់នគរបាលយុត្តិធម៌ និងជៀសវាងការចោទប្រកាន់គ្នាទៅវិញទៅមករវាងស្ថាប័ននគរបាល និងតុលាការ (នគរបាលចាប់ តុលាការលែង) សូមសម្តេចមេត្តាជួយជំរុញឱ្យអង្គការឧត្តមប្រឹក្សានៃអង្គចៅក្រមចេញឱ្យបានឆាប់ព្រោះរដ្ឋសភាបានអនុម័តច្បាប់នេះយូរហើយ ហើយព្រះករុណាជាម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈ ក៏ព្រះអង្គទ្រង់សព្វរាជហឫទ័យឱ្យអង្គការនេះមានដំណើរការយ៉ាងរូសរាន់ស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាយើងផងដែរ ។

សូមសម្តេច ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្របំផុតអំពីខ្ញុំ

ធ្វើនៅភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី១

<u>ចម្លងជូន</u>

-ឯកឧត្តម ចែម ស្គួន ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធមត